ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល
លេខ...២៩៤...ស្ធ ខ/ល

# សេចក្តីសម្រេច
## ស្តីពី
## ការតែងតាំងសមាសភាពលេខាធិការដ្ឋានរបស់គណៈប្រតិបត្តិ នៃគណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩

## រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងជាប្រធានគណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២១/០០៤ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- បានឃើញអនុក្រឹត្យលេខ ៣៧ អនក្រ.បក ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១ ស្តីពីវិធានការសុខាភិបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ ស្តីពីវិធានការរដ្ឋបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- បានឃើញអនុក្រឹត្យលេខ ៨៥ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ-១៩
- បានឃើញសេចក្តីសម្រេចលេខ ៦៧ សសរ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២១ ស្តីពីការតែងតាំងសមាសភាពគណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ-១៩
- បានឃើញសេចក្តីសម្រេចលេខ ៦៨ សសរ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២១ ស្តីពីការតែងតាំងសមាសភាពគណៈប្រចាំការនៃគណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ-១៩ ៸.



ទីស្តីការក្រសួងសុខាភិបាល អគារលេខ ៨០ វិថីសម្តេច ប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារៈ (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩

- បានឃើញសេចក្ដីសម្រេចលេខ ៦៩ សសរ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២១ ស្ដីពីសមាសភាព និង ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩
- យោងតាមតម្រូវការចាំបាច់របស់គណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩

## សម្រេច

**ប្រការ១ ..**

តែងតាំងសមាសភាពលេខាធិការដ្ឋានរបស់គណៈប្រតិបត្តិនៃគណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ ដូចមានរាយនាមខាងក្រោម៖

| | | |
|---|---|---|
| ១-ឯកឧត្តម **គឹម សន្តិភាព** | រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | ប្រធាន |
| ២-ឯកឧត្តម **កេង សុម៉ារិទ្ធ** | រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | អនុប្រធានប្រចាំការ |
| ៣-ឯកឧត្តមសាស្ត្រាចារ្យ **ថុង សុខហ៊ាន** | រដ្ឋលេខាធិការក្រសួងសុខាភិបាល | អនុប្រធាន |
| ៤-ឯកឧត្តមវេជ្ជបណ្ឌិត **ម៉ី សំអូរ** | រដ្ឋលេខាធិការក្រសួងសុខាភិបាល | អនុប្រធាន |
| ៥-លោកជំទាវ **ខៀវ សុផានី** | អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ | សមាជិក |
| ៦-ឯកឧត្តម **នាក់ សើគីរ៉េ** | អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ | សមាជិក |
| ៧-ឯកឧត្តម **តាន់ហ៊ាង ជាវ័ណ្ណ** | អគ្គនាយកនៃក្រសួងយុត្តិធម៌ | សមាជិក |
| ៨-ឯកឧត្តម **ញាន វណ្ណៈ** | នាយកខុទ្ទកាល័យរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | សមាជិក |
| ៩-ឯកឧត្តមវេជ្ជបណ្ឌិត **មាន ឈីវុន** | ទីប្រឹក្សាក្រសួងសុខាភិបាល | សមាជិក |
| ១០-ឯកឧត្តមវេជ្ជបណ្ឌិត **ម៉ៅ តាន់អ៊ាង** | ទីប្រឹក្សាក្រសួងសុខាភិបាល | សមាជិក |
| ១១-លោកជំទាវសាស្ត្រាចារ្យ **ឧុង រដ្ឋាវី** | ទីប្រឹក្សាក្រសួងសុខាភិបាល | សមាជិក |
| ១២-ឯកឧត្តមវេជ្ជបណ្ឌិត **ស៊ុង វិនតៈ** | ទីប្រឹក្សា និងជាប្រធាននាយកដ្ឋានក្រសួងសុខាភិបាល | សមាជិក |
| ១៣-ឯកឧត្តម **ប៉ែន វិសុទ្ធ** | ទីប្រឹក្សាក្រសួងយុត្តិធម៌ | សមាជិក |
| ១៤-លោក **ហ៊ុយ ឆេងតារាភ័ក្រ្ត** | អគ្គនាយករងក្រសួងសុខាភិបាល | សមាជិក |
| ១៥-លោកស្រី **សួរ ដានី** | អគ្គលេខាធិការរងក្រសួងយុត្តិធម៌ | សមាជិក |
| ១៦-លោក **លាវ ពិសិដ្ឋ** | អគ្គលេខាធិការរងក្រសួងយុត្តិធម៌ | សមាជិក |
| ១៧-លោក **ធិន ឧត្តរា** | នាយករងខុទ្ទកាល័យរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | សមាជិក |
| ១៨-លោកស្រី **ម៉ែន ផល្លីភា** | ព្រះរាជអាជ្ញាក្រសួងយុត្តិធម៌ | សមាជិក |
| ១៩-លោក **ហុក ខៀវ** | ប្រធាននាយកដ្ឋានក្រសួងសុខាភិបាល | សមាជិក |
| ២០-លោកវេជ្ជបណ្ឌិត **ស៊ុំ សារិទ្ធ** | ប្រធាននាយកដ្ឋានក្រសួងសុខាភិបាល | សមាជិក |
| ២១-លោក **សេង សត្យា** | ប្រធាននាយកដ្ឋានក្រសួងយុត្តិធម៌ | សមាជិក |

២២-លោកស្រី **សុន សុខាលីដា** ប្រធាននាយកដ្ឋានក្រសួងយុត្តិធម៌ សមាជិក

២៣-លោក **ម៉ែន ចំណាន** ប្រធាននាយកដ្ឋានក្រសួងយុត្តិធម៌ សមាជិក

២៤-លោកស្រី **ឌី ម៉ូឡានី** ប្រធាននាយកដ្ឋានក្រសួងយុត្តិធម៌ សមាជិក

២៥-លោកជំទាវ **គា ម៉ីម៉ី** អនុប្រធាននាយកដ្ឋានក្រសួងយុត្តិធម៌ សមាជិក

២៦-លោកស្រីឱសថការី **ទ៉ា ពុធនាថ** អនុប្រធាននាយកដ្ឋានក្រសួងសុខាភិបាល សមាជិក

២៧-កញ្ញា **ឈួន មរកត** ប្រធានលេខាធិការដ្ឋានក្រសួងយុត្តិធម៌ សមាជិក

២៨-លោក **លីម ម៉ិនហៀង** អនុប្រធានលេខាធិការដ្ឋានក្រសួងសុខាភិបាល សមាជិក

២៩-លោក **គុច គីមហេង** ជំនួយការរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ សមាជិក។

**ប្រការ២ ..**

លេខាធិការដ្ឋានរបស់គណៈប្រតិបត្តិនៃ **គ.អ.ក.** មានភារកិច្ចដូចតទៅ៖

- ទទួលបន្ទុកការងាររដ្ឋបាលទូទៅប្រចាំថ្ងៃរបស់គណៈប្រតិបត្តិនៃ **គ.អ.ក.**
- រៀបចំ និងសម្របសម្រួលកម្មវិធីការងារ កិច្ចប្រជុំ បេសកកម្ម និងពិធីការផ្សេងៗរបស់គណៈប្រតិបត្តិនៃ **គ.អ.ក.**
- ទទួលរបាយការណ៍សកម្មភាពប្រចាំថ្ងៃពីអនុគណៈកម្មការនានាចំណុះឱ្យ **គ.អ.ក.**, គណៈកម្មការប្រយុទ្ធនឹងជំងឺកូវីដ-១៩ ថ្នាក់រាជធានី-ខេត្ត និងយន្តការនានាចំណុះឱ្យ **គ.ប.ក.** ឬដែលអនុវត្តការងារពាក់ព័ន្ធនឹងការប្រយុទ្ធនឹងជំងឺកូវីដ-១៩
- ធ្វើទំនាក់ទំនងជាមួយអនុគណៈកម្មការនានាចំណុះឱ្យ **គ.អ.ក.**, គណៈកម្មការប្រយុទ្ធនឹងជំងឺកូវីដ-១៩ ថ្នាក់រាជធានី-ខេត្ត និងយន្តការនានាចំណុះឱ្យ **គ.ប.ក.** ឬដែលអនុវត្តការងារពាក់ព័ន្ធនឹងការប្រយុទ្ធនឹងជំងឺកូវីដ-១៩ ដើម្បីបម្រើឱ្យការងាររបស់គណៈប្រតិបត្តិនៃ **គ.អ.ក.**
- រៀបចំឯកសារ របាយការណ៍ និងកំណត់ហេតុនៃកិច្ចប្រជុំ និងកម្មវិធីផ្សេងៗរបស់គណៈប្រតិបត្តិនៃ **គ.អ.ក.**
- បូកសរុបរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំរបស់គណៈប្រតិបត្តិនៃ **គ.អ.ក.**
- អនុវត្តការងារផ្សេងទៀត តាមការប្រគល់ភារកិច្ចរបស់គណៈប្រតិបត្តិនៃ **គ.អ.ក.**។

**ប្រការ៣ ..**

លេខាធិការដ្ឋានរបស់គណៈប្រតិបត្តិនៃ **គ.អ.ក.** បំពេញការងាររបស់ខ្លួន ក្រោមការដឹកនាំផ្ទាល់របស់អនុប្រធានអចិន្ត្រៃយ៍គណៈប្រតិបត្តិនៃ **គ.អ.ក.** ស្របតាមមាត្រា៩ នៃអនុក្រឹត្យលេខ ៨៥ អនក្រ.បក ចុះថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ-១៩។

**ប្រការ៤ ..**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៥ ..**

គណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ គណៈប្រតិបត្តិនៃគណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ និងអនុគណៈកម្មការនានាចំណុះឱ្យគណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ ព្រមទាំងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសៅរ៍ ១០កើត ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២១

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

**និងជាប្រធាន គ.អ.ក.**

**ម៉ម ប៊ុនហេង**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- គណៈប្រចាំការនៃ **គ.ប.ក.**
- គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស
- គណៈកម្មការចំពោះកិច្ចទទួលបន្ទុកលទ្ធកម្មវ៉ាក់សាំងកូវីដ-១៩
- គណៈកម្មការប្រយុទ្ធនឹងជំងឺកូវីដ-១៩ ថ្នាក់រាជធានី-ខេត្ត
- ដូចប្រការ៥
- ឯកសារ កាលប្បវត្តិ